ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

កំពង់ផែស្វយ័តក្រុងព្រះសីហនុ

លេខ: ០១៥ សជណ/កសស

ខេត្តព្រះសីហនុ ថ្ងៃទី៣០ខែ ៥ ឆ្នាំ២០១១

# សេចក្តីជូនដំណឹង

## ប្រតិភូរាជរដ្ឋាភិបាល

## ទទួលបន្ទុកជាប្រធានអគ្គនាយកកំពង់ផែស្វយ័តក្រុងព្រះសីហនុ

**យោង** : ដោយផ្ទៃដីរបស់កំពង់ផែកាន់តែតូចចង្អៀតហើយបច្ចុប្បន្នទំនិញមានការកើនឡើង ប៉ុន្តែចរាចររថយន្តដឹកកុងតេន័រកកស្ទះជារឿយៗដែលបណ្តាលអោយសមត្ថភាពនៃការលើកដាក់របស់កំពង់ផែថយចុះ ។

- : ដោយប្រព័ន្ធ CTMS របស់ជប៉ុនតំរូវអោយរថយន្តដែលដឹកកុងតេន័រទំលាក់នៅទីលានរួច រថយន្តទទេត្រូវបើកចេញពីតំបន់កំពង់ផែ ។

- : តាមការចាំបាច់ក្នុងការរៀបចំកែសម្រួលសណ្តាប់ធ្នាប់ - ចរាចរក្នុងតំបន់កំពង់ផែ ។

## សូមជូនដំណឹងដល់

## លោក លោកស្រី ប្រធានក្រុមហ៊ុនរថយន្តដឹកជញ្ជូនទាំងអស់ ដែលមានរថយន្តដឹកកុងតេន័រចេញ-ចូលកំពង់ផែមេត្តាជ្រាបថា:

ចាប់ពីថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០១១ រាល់រថយន្តដឹកកុងតេន័រដែលចេញ-ចូលតាមច្រក៣ ត្រូវអនុវត្តផែនការដូចខាងក្រោម ៖

១ - ចំពោះរថយន្តដឹកកុងតេន័រនាំចេញ (Export) ទាំងអស់ដែលត្រូវចូលស្កេននៅច្រក៣ គឺមិនទាន់ព្រីនឯកសារ (EIR-IN) ជូនទេ លុះត្រាតែរថយន្តដឹកកុងតេន័រ (Export) ទាំងអស់នោះចូលស្កេនរួចរាល់ ហើយបង្ហាញលិខិតបញ្ជាក់ថាកុងតេន័ររបស់ខ្លួនបានចូលស្កេនរួច ទើបបុគ្គលិកច្រក៣ព្រីនឯកសារ (EIR-IN) ជូន ដើម្បីដឹកកុងតេន័រទៅទំលាក់នៅទីលាន ។

២ - រាល់រថយន្តដឹកកុងតេន័រមានទំនិញ ឬសំបកនាំចេញ (Export) ទាំងអស់ដែលចូលតាមច្រក៣ ហើយទំលាក់កុងតេន័រនៅទីលានរួច រថយន្តទទេត្រូវបើកចេញតាមច្រក២ និងចូលតាមច្រក៣ វិញ ដើម្បីចូលដឹកកុងតេន័រនាំចូល (Import) នៅទីលាន ។

អាស្រ័យហេតុដូចបានជំរាបជូនខាងលើ សូមលោក លោកស្រី ប្រធានក្រុមហ៊ុនរថយន្តដឹកជញ្ជូនទាំងអស់មេត្តាជ្រាបនិងចូលរួមសហការអនុវត្តតាមសេចក្តីជូនដំណឹងនេះតទៅ ៕

**ប្រតិភូរាជរដ្ឋាភិបាល**

**ទទួលបន្ទុកជាប្រធានអគ្គនាយក**

PORT AUTONOME DE SIHANOUKVILLE

ឡូ សុផាត

**ចំលងជូន**

- ឯកឧត្តម លោកអគ្គនាយករង កសស
- គ្រប់នាយកដ្ឋានពាក់ព័ន្ធចំណុះ ក.ស.ស
- ទីស្នាក់ការគយ និងរដ្ឋាករ ប្រចាំ ក.ស.ស
- ទីស្នាក់ការកាំកុងត្រូលប្រចាំ ក.ស.ស
- ប៉ុស្តិ៍នគរបាលច្រកទ្វារអន្តរជាតិកំពង់ផែស្វយ័តក្រុងព្រះសីហនុ
  " ដើម្បីសហការ "
- ឯកសារ -កាលប្បវត្តិ

តំរិវិថី សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ
Tarak Vithei Samdech Akka Moha Sena Techo HUN SEN
ទូរស័ព្ទ : (855) 34 933 416 ទូរសារ : (855) 34 933 693
Tel : (855) 34 933 416 Fax : (855) 34 933 693
www.pas.gov.kh